ក្រសួងសុខាភិបាល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ...០៦៦...ស.ន.ស

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ ០៣ ឆ្នាំ ២០០១

## សេចក្តីណែនាំ
## ស្តីពី
## នីតិវិធីនៃការតែងតាំងតំណែងឋានៈមន្ត្រីរាជការ

កន្លងមកក្រសួងសុខាភិបាលសង្កេតឃើញថា គ្រប់មន្ទីរសុខាភិបាលខេត្ត-ក្រុង បានអនុវត្តល្អប្រសើរនូវសិទ្ធិនៃការតែងតាំងតំណែងឋានៈ និងកែសម្រួលភារកិច្ចមន្ត្រីរាជការក្រោមឱវាទមន្ទីរ ដែលតែងតែប្រព្រឹត្តទៅជាបន្តបន្ទាប់ ដោយផ្អែកតាមលិខិតលេខ ១២១០ ស.កបត ចុះថ្ងៃទី ១២.០៧.៩៤ និងសារាចរលេខ ១៩០ ស.កបត ចុះថ្ងៃទី ១៣.១២.៩៤ របស់ក្រសួងសុខាភិបាល ។ ប៉ុន្តែចាប់ពី ពេលនេះតទៅដើម្បីឲ្យស្របតាមសារាចរណែនាំលេខ ០២ សរណន ចុះថ្ងៃទី ១៥.០៣.៩៩ និងសារាចរ ណែនាំលេខ ១០ សរណន ចុះថ្ងៃទី ២៨.០៦.៩៩ របស់រាជរដ្ឋាភិបាល ស្តីពីនីតិវិធីនៃការតែងតាំងមន្ត្រីរាជការ ស៊ីវិល ក្រសួងសុខាភិបាល សូមធ្វើការណែនាំដល់គ្រប់មន្ទីរសុខាភិបាលខេត្ត-ក្រុងដូចខាងក្រោម :

**១. សិទ្ធិនិងសមត្ថកិច្ចនៃការតែងតាំង :**

ក- មុខងារ.ឋានៈ របស់មន្ត្រីរាជការដែលត្រូវតែងតាំងដោយប្រកាសក្រសួងសុខាភិបាលមានៈ

- ប្រធាន- អនុប្រធានការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ និងថ្នាក់ប្រហាក់ប្រហែល ។
- ប្រធាន- អនុប្រធានការិយាល័យជុំវិញមន្ទីរ ។

ខ- មុខងារ.ឋានៈ របស់មន្ត្រីរាជការដែលត្រូវតែងតាំងដោយ [illegible] :

- ប្រធាន- អនុប្រធាន ប៉ុស្តិ៍សុខភាព
- ប្រធាន- អនុប្រធាន មណ្ឌលសុខភាព
- អនុប្រធានមន្ទីរពេទ្យបង្អែក

គ- មុខងារ.ឋានៈ របស់មន្ត្រីរាជការដែលត្រូវតែងតាំងដោយលិខិតបង្គាប់ការរបស់ការិយាល័យស្រុកប្រតិបត្តិ មានៈ

- ប្រធាន- អនុប្រធានផ្នែកក្នុងមន្ទីរពេទ្យបង្អែក
- ប្រធាន- អនុប្រធានផ្នែកជុំវិញការិយាល័យស្រុកប្រតិបត្តិ
- ប្រធាន- អនុប្រធានផ្នែកក្នុងមណ្ឌលសុខភាពនិងប៉ុស្តិ៍សុខាភិបាល

## ២- នីតិវិធីនៃការតែងតាំង :

- ការតែងតាំងតំណែងឋានៈមន្ត្រីរាជការក្នុងមុខងារដែលមានចែងក្នុងចំណុចទី១ ត្រូវប្រព្រឹត្តទៅតាមអង្គភាពលេខ និង របនាសម្ព័ន្ធរបស់អង្គភាព។
- ការតែងតាំងតំណែងឋានៈមន្ត្រីនៅក្នុងចំណុច ១ក មន្ទីរសុខាភិបាលខេត្ត- ក្រុងត្រូវលើកសំណើមកក្រសួងតាមឋានានុក្រមរដ្ឋបាលដែលភ្ជាប់មកជាមួយនូវសំណុំបែបបទដូចមានក្នុងឧបសម្ព័ន្ធនៃសេចក្តីណែនាំនេះ ។
- ចំពោះការតែងតាំងតំណែងឋានៈមន្ត្រីរាជការនៅក្នុងចំណុច ១ខ និង ១គ អង្គភាពរបស់សាមីជនក៏ត្រូវលើកសំណើសុំទៅថ្នាក់មានសមត្ថកិច្ចតែងតាំង តាមឋានានុក្រមដែរ។
- ចំពោះលក្ខណៈសម្បត្តិរបស់សាមីជនដែលត្រូវស្នើសុំតែងតាំង :
  - មានសញ្ញាប័ត្រជំនាញ សមស្របតាមមុខតំណែងដែលត្រូវស្នើសុំតែងតាំង
  - មានស្នាដៃនិងបទពិសោធន៍ក្នុងការបំពេញមុខងារតាមលំដាប់លំដោយ
  - បានបំពេញមុខងារភារៈកិច្ចបង្ហាញឲ្យឃើញនូវការទុកចិត្តពីថ្នាក់លើ មានការគាំទ្រពីថ្នាក់ក្រោម និងស្មារតីទទួលខុសត្រូវ ។
  - មានសីលធម៌ល្អ ក្នុងការទំនាក់ទំនងជាមួយថ្នាក់លើនិងថ្នាក់ក្រោម ជាគំរូលើគ្រប់វិស័យក្នុងការប្រព្រឹត្តរាល់សកម្មភាពសង្គម ។

៣- ចំពោះមន្ត្រីរាជការដែលមានមុខងានិងឋានៈដូចបានចែងក្នុងចំណុចទី ១ក ហើយដែលកំពុងស្ថិតក្នុងមុខដំណែងពិតប្រាកដក្នុងអង្គការលេខនិងរចនាសម្ព័ន្ធ របស់មន្ទីរសុខាភិបាលខេត្ត-ក្រុងនោះ មន្ទីរសុខាភិបាលខេត្ត-ក្រុងត្រូវលើកសំណើមកក្រសួងសុខាភិបាល ដើម្បីពិនិត្យនិងសំរេចធ្វើនិយ័តកម្មជូន ។

បន្ទាប់ពីបានទទួលសេចក្តីណែនាំនេះ គ្រប់មន្ទីរសុខាភិបាលខេត្ត-ក្រុងត្រូវរៀបចំអនុវត្តតាមខ្លឹមសារខាងលើ ដោយការទទួលខុសត្រូវ និងឲ្យបានប្រសិទ្ធិភាពខ្ពស់ ។

ចម្លង:
-ក្រសួងមុខងារសាធារណៈ

វេជ្ជ.អ៊ឹង_ហ៊ុត